# MEMORIAL HERMANN SURGICAL HOSPITAL KINGWOOD
# គោលនយោបាយ

**ឈ្មោះគោលនយោបាយ:** គោលនយោបាយស្តីពីជំនួយហិរញ្ញវត្ថុ

**កាលបរិច្ឆេទបោះពុម្ពផ្សាយ៖** 02/11/2019
**កំណែ៖** 3

---

## គោលបំណងគោលនយោបាយ៖

គោលបំណងនៃគោលនយោបាយជំនួយហិរញ្ញវត្ថុ (“FAP”) នេះ គឺដើម្បីប្រកាសអោយដឹងនូវវិធីសាស្ត្រជាប្រព័ន្ធក្នុងការកំណត់ និងផ្តល់ជំនួយហិរញ្ញវត្ថុដល់អ្នកដែល Memorial Hermann Surgical Hospital Kingwood (“MHSHK”) បម្រើនៅក្នុងសហគមន៍របស់ខ្លួន។

MHSHK គឺជាសាខារបស់ Memorial Hermann Health System (MHHS), ដែលបម្រើឱ្យគោលបំណងលើកលែងពន្ធរបស់ MHHS បន្ថែម ។ MHHS ដំណើរការក្រមប្រាក់ចំណូលផ្ទៃក្នុង § 501(c)(3) មន្ទីរពេទ្យដែលមានអាជ្ញាប័ណ្ណរដ្ឋ ដែលបម្រើតម្រូវការការថែទាំសុខភាព នៅ Harris, Montgomery, Fort Bend និងតំបន់ជុំវិញ។ MHSHK ប្តេជ្ញាផ្តល់ផលប្រយោជន៍សហគមន៍ក្នុងទម្រង់ជាជំនួយហិរញ្ញវត្ថុដោយមិនរើសអើងដល់បុគ្គលគ្មានធានារ៉ាប់រង និង មានធានារ៉ាប់រងមិនគ្រប់គ្រាន់ ដែលពួកគាត់ត្រូវការជំនួយបន្ទាន់ ឬសេវាផ្នែកវេជ្ជសាស្ត្រចាំបាច់ដោយមិនគិតពីសមត្ថភាពរបស់អ្នកជំងឺក្នុងការទូទាត់ប្រាក់។

## វិសាលភាព៖

FAP នេះ អនុវត្តសម្រាប់ Memorial Hermann Surgical Hospital Kingwood, មន្ទីរពេទ្យដែលមានអាជ្ញាប័ណ្ណរដ្ឋ ដែលបម្រើឱ្យគោលបំណងលើកលែងពន្ធបន្ថែមរបស់ MHHS ។

## សេចក្តីថ្លែងគោលនយោបាយ៖

1. ស្របតាមគុណតម្លៃរបស់ MHSHK នៃសេចក្តីមេត្តា និងការទទួលខុសត្រូវ វាគឺជាគោលនយោបាយរបស់ MHSHK ក្នុងការផ្តល់ជំនួយហិរញ្ញវត្ថុដល់អ្នកជំងឺដែលត្រូវការ។ លើសពីនេះ គោលបំណងនៃ FAP នេះគឺដើម្បីផ្តល់នូវក្របខ័ណ្ឌដែលជំនួយហិរញ្ញវត្ថុត្រូវបានផ្តល់ជូនអ្នកជំងឺដើម្បីទទួលបានការព្យាបាលបន្ទាន់ ឬចាំបាច់ផ្នែកវេជ្ជសាស្ត្រដែលផ្តល់ដោយ MHSHK។

2. FAP នេះ កំណត់លក្ខណវិនិច្ឆ័យជាក់លាក់ និងដំណើរការនៃការដាក់ពាក្យសុំដែល MHSHK នឹងពង្រីកជំនួយហិរញ្ញវត្ថុដល់បុគ្គលដែលមិនអាចទូទាត់ឱ្យបានពេញលេញសម្រាប់សេវាកម្មដែលបានផ្តល់ជូន។

3. FAP នេះអនុវត្តចំពោះការថែទាំចាំបាច់វេជ្ជសាស្ត្រ ឬបន្ទាន់ដែលផ្តល់ដោយ MHSHK។ FAP នេះមិនត្រូវបានចងលើអ្នកផ្តល់សេវាវេជ្ជសាស្ត្រនៅក្រៅមន្ទីរពេទ្យ

និងមិនអនុវត្តចំពោះសេវាគ្រូពេទ្យឡើយ។ អ្នកអាចស្វែងរកបញ្ជីអ្នកផ្តល់សេវាសង្គ្រោះបន្ទាន់ ឬការថែទាំចាំបាច់ផ្នែកវេជ្ជសាស្ត្រផ្សេងទៀតនៅក្នុងមន្ទីរពេទ្យដែល FAP ធានារ៉ាប់រងសេវាកម្មទាំងនោះ និងបញ្ជីអ្នកផ្តល់សេវាដែល FAP មិនធានារ៉ាប់រងសេវាកម្មទាំងនោះ នៅលើគេហទំព័ររបស់យើងនៅ៖ http://www.memorialhermannkingwood.com/financial-assistance-program/. ច្បាប់ចម្លងដោយឥតគិតថ្លៃក៏អាចរកបានតាមការស្នើសុំនៅផ្នែកសង្គ្រោះបន្ទាន់ និងកន្លែងចុះឈ្មោះរបស់មន្ទីរពេទ្យផងដែរ។ ច្បាប់ចម្លងដោយឥតគិតថ្លៃក៏អាចរកបានបានផងដែរតាមរយៈអ៊ីម៉ែល ឬដោយហៅទូរស័ព្ទលេខ (281) 312-4012 or 281-312-4000 ជម្រើសទី 5 ។

4. FAP ពណ៌នាអំពីលក្ខណៈវិនិច្ឆ័យដែលត្រូវបានប្រើប្រាស់ដោយ MHSHK ក្នុងការគណនាចំនួនទឹកប្រាក់នៃការបញ្ចុះតម្លៃជំនួយផ្នែកហិរញ្ញវត្ថុប្រសិនបើមានវិធានការ MHSHK នឹងយកទៅផ្សព្វផ្សាយជាសាធារណៈដល់ FAP នេះនៅក្នុងសហគមន៍ដែលបម្រើដោយ MHSHK ដំណើរការដែលត្រូវបានប្រើប្រាស់ដោយ MHSHK ដើម្បីកំណត់សិទ្ធិទទួលបានហិរញ្ញវត្ថុ និងដំណើរការស្នើសុំជំនួយហិរញ្ញវត្ថុ។ ចំណាត់ការនានាដែល MHSHK អាចនឹងទទួលក្នុងករណីដែលការមិនទូទាត់ប្រាក់ត្រូវបានសេចក្តីថ្លែងនានៅក្នុងគោលនយោបាយដាច់ដោយឡែក គោលនយោបាយបង់ប្រាក់និងប្រមូលប្រាក់របស់ MHSHK។ គោលនយោបាយនេះអាចទាញយកបាននៅលើគេហទំព័រ MHSHK៖ http://www.memorialhermannkingwood.com/financial-assistance-program/ ឬច្បាប់ចម្លងដោយឥតគិតថ្លៃគឺមាននៅក្នុងផ្នែកសង្គ្រោះបន្ទាន់ និងកន្លែងចុះឈ្មោះរបស់មន្ទីរពេទ្យ។ ច្បាប់ចម្លងដោយឥតគិតថ្លៃក៏អាចរកបានបានផងដែរតាមរយៈអ៊ីម៉ែល ឬការហៅទូរស័ព្ទលេខ (281) 312-4012 or 281-312-4000 ជម្រើសទី 5 ។

5. ដើម្បីមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុអ្នកជំងឺត្រូវតែបំពេញ និងដាក់ពាក្យសុំជំនួយហិរញ្ញវត្ថុដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធចាំបាច់។ ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុគឺមិនត្រូវយូរជាង 240 ថ្ងៃ ក្រោយពីកាលបរិច្ឆេទនៃរបាយការណ៍បង់ប្រាក់ដំបូងដែលបានផ្ញើផ្ញើផ្ញើសម្រាប់សេវាកម្មដែលអ្នកស្នើសុំជំនួយហិរញ្ញវត្ថុឡើយ។ ការលើកលែងអាចត្រូវបានផ្តល់ជូនដូចដែលបានពណ៌នានៅក្នុងនីតិវិធីផ្នែកទី 9 ។ គ្មានអ្វីនៅក្នុង FAP នេះមានអាទិភាពជាងច្បាប់ ឬបទប្បញ្ញត្តិសហព័ន្ធ រដ្ឋ ឬក្នុងស្រុក ដែលបានចូលជាធរមានក្នុងពេលបច្ចុប្បន្ន ឬចូលជាធរមាននាពេលអនាគត។

6. ចំនួនទឹកប្រាក់ដែលបានបង់ដោយអ្នកជំងឺលើសពីចំនួនទឹកប្រាក់ដែលត្រូវបង់បន្ទាប់ពីការបញ្ចុះតម្លៃជំនួយហិរញ្ញវត្ថុត្រូវបានអនុវត្តនឹងត្រូវបានសងប្រាក់វិញសម្រាប់គ្រប់ដំណាក់កាលដែលមានលក្ខណៈគ្រប់គ្រាន់។

7. សិទ្ធិអំណាចចុងក្រោយក្នុងការកំណត់ថាតើ MHSHK បានព្យាយាមគ្រប់គ្រាន់ក្នុងការកំណត់សិទ្ធិទទួលបាន FAP សម្រេចលើការិយាល័យសេវាកម្មអាជីវកម្មសម្រាប់អ្នកជំងឺរបស់ MHSHK។ FAP នេះមានគោលបំណងផ្តល់អត្ថប្រយោជន៍ដល់សហគមន៍របស់ MHSHK ស្របជាមួយនឹងគុណតម្លៃនៃសេចក្តីមេត្តា និងការទទួលខុសត្រូវ។ អត្ថិភាពនៃ FAP នេះមិនមែនជាការផ្តល់ជំនួយហិរញ្ញវត្ថុដល់អ្នកជំងឺណាម្នាក់ទេ និងមិនបង្កើតនូវសិទ្ធិ ឬកាតព្វកិច្ចតាមកិច្ចសន្យាឡើយ។ FAP នេះអាចនឹងត្រូវធ្វើបច្ចុប្បន្នភាពដោយ MHSHK នាពេលអនាគត និងអនុម័តដោយក្រុមប្រឹក្សាភិបាល ឬអ្នកគ្រប់គ្រងរបស់ខ្លួនក្នុងឆន្ទានុសិទ្ធិតែមួយគត់របស់ខ្លួន។

8. គោលនយោបាយ និងនីតិវិធីនានាដែលមានចែងនៅទីនេះមានបំណងអនុវត្តតាមបទប្បញ្ញត្តិរដ្ឋរដ្ឋតិចសាស និង I.R.C § 501(r) និងគោលការណ៍ណែនាំពាក់ព័ន្ធ។

**<u>វាក្យស័ព្ទ & និយមន័យ៖</u>**

1. *ពាក្យស្នើសុំ៖* មានន័យថាពាក្យស្នើសុំជំនួយហិរញ្ញវត្ថុត្រូវបំពេញដោយអ្នកជំងឺ។

2. *អំឡុងពេលស្នើសុំ៖* ក្នុងអំឡុងពេលស្នើសុំ MHSHK នឹងទទួល និងដំណើរការពាក្យស្នើសុំជំនួយហិរញ្ញវត្ថុ។ អំឡុងពេលស្នើសុំចាប់ផ្តើមពីកាលបរិច្ឆេទនៃការផ្តល់សេវាថែទាំដល់បុគ្គល និងបញ្ចប់នៅថ្ងៃទី 240 បន្ទាប់ពីកាលបរិច្ឆេទនៃការចេញរបាយការណ៍គិតប្រាក់ដំបូងសម្រាប់សេវាថែទាំនោះ៖

3. *ចំនួនដែលត្រូវបង់ជាទូទៅ (AGB)៖* អ្នកជំងឺដែលមានលក្ខណៈគ្រប់គ្រាន់សម្រាប់ទទួលបានជំនួយហិរញ្ញវត្ថុនឹងមិនត្រូវបានគិតប្រាក់បន្ថែមសម្រាប់ការសង្គ្រោះបន្ទាន់ ឬការថែទាំសុខភាពចាំបាច់ជាងចំនួនដែលត្រូវបង់ជាទូទៅ (AGB) ដល់អ្នកជំងឺដែលមានការធានារ៉ាប់រង

    a. ភាគរយ AGB របស់ MHSHK គណនាដោយប្រើវិធីសាស្ត្រ "មើលក្រោយ" ដែលត្រូវយកចំនួនសរុបនៃការទូទាត់ថ្លៃសេវាកម្មសម្រាប់ Medicare មកចែកនឹងការគិតថ្លៃសរុបសម្រាប់ការទាមទារទាំងនោះសម្រាប់រយៈពេល 12 ខែមុន។ ការបញ្ចុះតម្លៃដែលផ្តល់ជូនអ្នកជំងឺដែលមានសិទ្ធិទទួលជំនួយហិរញ្ញវត្ថុនឹងត្រូវបានពិនិត្យឡើងវិញជាមួយនឹងការកម្រិតភាគរយ AGB ដើម្បីធានាថាអ្នកជំងឺមិនត្រូវបានគេគិតប្រាក់លើសពី AGB ។

    b. ចំនួនជាភាគរយ AGB អាចរកបាននៅក្នុងសេចក្តីថ្លែង A - ការគណនានៃ FAP នូវចំនួនដែលត្រូវបង់ជាទូទៅ។

    c. ចំនួនជាភាគរយនៃ AGB ដែលបានកែសម្រួលឡើងវិញនឹងត្រូវគណនាជារៀងរាល់ឆ្នាំ និងអនុវត្តត្រឹមថ្ងៃទី 120 បន្ទាប់ពីការចាប់ផ្តើមនៃឆ្នាំប្រតិទិន។

4. *ចំណូលគ្រួសារសរុបប្រចាំឆ្នាំ៖* ចំនួនសរុបនៃប្រាក់ចំណូលប្រចាំឆ្នាំរបស់គ្រួសារនិងអត្ថប្រយោជន៍ជាសាច់ប្រាក់ពីគ្រប់ប្រភពទាំងអស់មុនពេលបង់ពន្ធ ដកនឹងការចំណាយធ្វើឡើងណាមួយសម្រាប់ការគាំទ្រកុមារដែលអាចរាយការណ៍ទៅសេវាកម្មប្រាក់ចំណូលផ្ទៃក្នុងរបស់សហរដ្ឋអាមេរិក។ ចំណូលគ្រួសាររួមបញ្ចូលប៉ុន្តែមិនត្រូវបានកំណត់ចំពោះប្រាក់ចំណូល ប្រាក់សំណងលើការគ្មានការងារធ្វើរបស់កម្មករនិយោជិត។ សំណង សន្តិសុខសង្គម ប្រាក់ចំណូលសន្តិសុខបន្ថែម ប្រាក់រដ្ឋ (សម្រាប់ជួយអ្នកទ័លក្រ) ប្រាក់សំណងលើអតីតយុទ្ធជន ការធានារ៉ាប់រងលើអ្នកនៅរស់រានមានជីវិតពីគ្រោះថ្នាក់ សោធននិវត្តន៍ឬប្រាក់ចូលនិវត្តន៍ ការប្រាក់ អាហារកិច្ច ការផ្តល់អាហារូបត្ថម្ភការគាំទ្រកុមារនិងប្រភពផ្សេងៗទៀត។

5. *សេវាកម្មជ្រើសរើស៖* សេវាដែលត្រូវព្យាបាលលក្ខខណ្ឌដែលមិនត្រូវការការយកចិត្តទុកដាក់ភ្លាមៗ។ សេវាកម្មដែលជ្រើសរើសរួមមាននីតិវិធីដែលមានអត្ថប្រយោជន៍ដល់អ្នកជំងឺប៉ុន្តែមិនបន្ទាន់និងរួមមានសេវាសុខភាពចាំបាច់ និងសេវាសុខភាពមិនចាំបាច់ដូចជាការវះកាត់កែសម្ផស្ស និងវះកាត់ធ្មេញដែលអនុវត្តដើម្បីតែកែលម្អរូបរាងប៉ុណ្ណោះ ឬនីតិវិធីជ្រើសរើសផ្សេងទៀតដែលមិនបានគ្របដណ្តប់ដោយផែនការធានារ៉ាប់រងសុខភាព។ សេវាកម្មជ្រើសរើសដែលមិនចាំបាច់សម្រាប់សុខភាពនឹងមិនត្រូវបានពិចារណាសម្រាប់ការផ្តល់ជំនួយហិរញ្ញវត្ថុឡើយ។

6. *សេវាកម្មបន្ទាន់៖* សេវាដែលបានផ្តល់ជូនអ្នកជំងឺចំពោះ សេវាដែលបានផ្តល់ជូនអ្នកជំងឺចំពោះស្ថានភាពជម្ងឺដែលមានរោគសញ្ញាស្រួចស្រាវធ្ងន់ធ្ងរ (រួមទាំងការឈឺចាប់ធ្ងន់ធ្ងរ) គេរំពឹងថាការមិនបានយកចិត្តទុកដាក់លើសុខភាពភ្លាមៗដូចនោះអាចនាំឱ្យសុខភាពរបស់បុគ្គលម្នាក់ៗ (ឬស្ត្រីមានផ្ទៃពោះ ស្ត្រី ឬកូនដែលមិនទាន់កើតរបស់នាង) មានគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬបង្កឱ្យមានការខូចខាតធ្ងន់ធ្ងរដល់មុខងាររាងកាយ ឬធ្វើឱ្យខូចមុខងារធ្ងន់ធ្ងរនៃសរីរាង្គរាងកាយ ឬផ្នែកណាមួយ។

7. *សកម្មភាពប្រមូលប្រាក់បន្ថែម (ECAs)៖* សកម្មភាពទាំងនេះគឺជាសកម្មភាពប្រមូលដែលតម្រូវឱ្យមានដំណើរការច្បាប់ ឬតុលាការ ហើយក៏អាចរួមមានសកម្មភាពផ្សេងទៀតដូចជា ការលក់បំណុលទៅឱ្យភាគីមួយទៀត ឬការរាយការណ៍អំពីព័ត៌មានមិនល្អទៅភ្នាក់ងារឥណទាន ឬមន្ទីរការិយាល័យ។ MHSHFC មិនចូលរួមក្នុង ECAs ទេ ហើយក៏មិនអនុញ្ញាតឱ្យភ្នាក់ងារប្រមូលប្រាក់របស់ខ្លួនចូលរួមក្នុង ECAs ដែរ។ ព័ត៌មានបន្ថែមអំពីគោលនយោបាយប្រមូលរបស់ MHSHFC អាចរកបាននៅក្នុងគោលនយោបាយប្រមូល និងទូទាត់ប្រាក់ MHSHFC ដាច់ដោយឡែករបស់ MHSHFC ហើយគោលនយោបាយនេះអាចរកបានដោយសេរីនៅលើបណ្តាញអនឡាញនៅ៖ http://www.memorialhermannkingwood.com/financial-assistance-program/ ឬច្បាប់ចម្លងដោយឥតគិតថ្លៃអាចរកបានតាមការស្នើសុំក្នុងផ្នែកសង្គ្រោះបន្ទាន់ និងនៅកន្លែងចុះឈ្មោះរបស់មន្ទីរពេទ្យ ឬទូរស័ព្ទទៅលេខ (281) 312-4012 ឬ 281-312-4000 ជម្រើសទី 5 ។

8. *គ្រួសារ៖* អ្នកជំងឺ សហព័ន្ធអ្នកជំងឺ/ដៃគូរួមរស់ជាមួយគ្នារបស់អ្នកជំងឺ ឪពុកម្តាយ ឬអាណាព្យាបាលរបស់អ្នកជំងឺ (ក្នុងករណីអ្នកជំងឺជាអនីតិជន) និងអ្នកនៅក្នុងបន្ទុកណាម្នាក់ដែលបានអះអាងអំពីរបាយការណ៍ចំណូលសម្រាប់បង់ពន្ធរបស់អ្នកជំងឺ ឬឪពុកម្តាយនិងរស់នៅក្នុងផ្ទះអ្នកជំងឺ ឬឪពុកម្តាយ ឬអាណាព្យាបាលរបស់គាត់។

9. *កម្រិតភាពក្រីក្រសហព័ន្ធ ("FPL")៖* កម្រិតនៃប្រាក់ចំណូលដែលបុគ្គលម្នាក់ត្រូវបានចាត់ទុកថាស្ថិតនៅក្នុងកម្រិតនៃភាពក្រីក្រ។ កម្រិតប្រាក់ចំណូលនេះខុសៗគ្នាទៅតាមទំហំគ្រួសារ។ កម្រិតភាពក្រីក្រត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំដោយនាយកដ្ឋានសេវាសុខាភិបាល និងមនុស្សរបស់សហរដ្ឋអាមេរិក និងបានចុះផ្សាយក្នុងបញ្ជីសហព័ន្ធ។ សម្រាប់គោលបំណងនៃ FAP នេះ កម្រិតភាពក្រីក្រដែលបានបង្ហាញនៅក្នុងគោលការណ៍ណែនាំដែលបានបោះពុម្ពផ្សាយនេះបង្ហាញពីចំណូលសរុប។ FPL ដែលត្រូវបានប្រើប្រាស់សម្រាប់គោលបំណងនៃ FAP

នេះនឹងត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ FPLs បច្ចុប្បន្នអាចរកបាននៅក្នុងសេចក្តីថ្លែង B - គោលការណ៍ណែនាំភាពក្រីក្ររបស់សហព័ន្ធនៃ FAP។

10. *ជំនួយហិរញ្ញវត្ថុ៖* ជំនួយហិរញ្ញវត្ថុមានន័យថាជំនួយដែលផ្តល់ដោយ MHSHK ដល់អ្នកជំងឺដែលបំពេញលក្ខណ្ឌហិរញ្ញវត្ថុ និងលក្ខណ្ឌផ្សេងទៀតក្នុងការទទួលបានសិទ្ធនេះ ដូចដែលបានកំណត់នៅក្នុង FAP ដើម្បីជួយពួកគេឱ្យទទួលបានធនធានហិរញ្ញវត្ថុចាំបាច់ក្នុងការចំណាយលើថ្លៃសេវាថែទាំសុខភាពចាំបាច់ ឬបន្ទាន់ដែលផ្តល់ដោយ MHSHK ក្នុងមន្ទីរពេទ្យដែលបានកំណត់។ អ្នកជំងឺដែលមានសិទ្ធិទទួលបានអាចរួមមានអ្នកជំងឺដែលគ្មានធានារ៉ាប់រង អ្នកជំងឺដែលមានចំណូលទាប និងអ្នកជំងឺដែលមានធានារ៉ាប់រងខ្លះ ប៉ុន្តែមិនអាចបង់ថ្លៃសេវាព្យាបាលរបស់ខ្លួនដែលនៅសេសសល់ខ្លះ ឬទាំងអស់។

11. *សេវាសុខភាពចាំបាច់៖* សេវាកម្ម ឬការផ្គត់ផ្គង់ដែលត្រូវបានផ្តល់សម្រាប់ការធ្វើរោគវិនិច្ឆ័យ ការថែទាំដោយផ្ទាល់ និងការព្យាបាលស្ថានភាពសុខភាព បំពេញតាមស្តង់ដារនៃការអនុវត្តន៍វេជ្ជសាស្ត្រល្អនៅក្នុងតំបន់មូលដ្ឋានត្រូវបានធានារ៉ាប់រង និងចាត់ទុកថាជារឿងចាំបាច់ខាងវេជ្ជសាស្ត្រដោយកម្មវិធី Medicare និង Medicaid និងមិនមែនដើម្បីភាពងាយស្រួលដល់អ្នកជំងឺ ឬគ្រូពេទ្យជាចម្បងឡើយ។ សេវាចាំបាច់ផ្នែកវេជ្ជសាស្ត្រមិនរាប់បញ្ចូលការវះកាត់កែសម្ផស្ស ឬសេវាមិនមែនវេជ្ជសាស្ត្រដូចជាសេវាសង្គម អប់រំ ឬវិជ្ជាជីវៈ។

12. *សេចក្តីសង្ខេបជាភាសាសាមញ្ញងាយយល់ ("PLS")៖* សេចក្តីសង្ខេបជាភាសាសាមញ្ញងាយយល់នៃ FAP របស់ MHSHFC រួមមាន៖ (a) ការពណ៌នាសង្ខេបអំពីលក្ខខណ្ឌដែលមានសិទ្ធិទទួលបាន និងជំនួយដែលផ្តល់ឱ្យ (b) បញ្ជីគេហទំព័រ និងទីតាំងភូមិសាស្ត្រដែលអាចទទួលយកពាក្យស្នើសុំជំនួយហិរញ្ញវត្ថុ (c) សេចក្តីណែនាំអំពីរបៀបទទួលបានច្បាប់ចម្លងជាក្រដាសឥតគិតថ្លៃរបស់ FAP (d) ព័ត៌មានទាក់ទងសម្រាប់ជំនួយទាក់ទងនឹងដំណើរការដាក់ពាក្យស្នើសុំ (e) ការមានការបកប្រែ FAP និងឯកសារពាក់ព័ន្ធទៅជាភាសាផ្សេងៗ និង (f) សេចក្តីបញ្ជាក់ថា អ្នកជំងឺដែលត្រូវបានកំណត់ថាមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុនឹងមិនត្រូវបានគិតលើសពីចំនួនដែលត្រូវបង់ជាទូទៅសម្រាប់សង្គ្រោះបន្ទាន់ ឬសេវាចាំបាច់ផ្នែកវេជ្ជសាស្ត្រ។

13. *កិច្ចខិតខំប្រឹងប្រែងសមហេតុផល៖* MHSHK នឹងខិតខំប្រឹងប្រែងសមហេតុផលដើម្បីផ្តល់ការជូនដំណឹងដល់អ្នកជំងឺអំពី FAP របស់ MHSHK ដោយផ្តល់ជូននូវសេចក្តីសង្ខេបភាសាធម្មតានៃ FAP ដល់អ្នកជំងឺមុនពេលចេញពីមន្ទីរពេទ្យ។ លើសពីនេះ MHSHK នឹងចាត់វិធានការដូចខាងក្រោមដើម្បីជូនដំណឹងដល់អ្នកជំងឺអំពី MHSHK FAP៖

    a. *ពាក្យស្នើសុំមិនពេញលេញ៖* ប្រសិនបើអ្នកជំងឺ និង/ឬក្រុមគ្រួសារដាក់ពាក្យសុំមិនពេញលេញ MHSHK នឹងផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរដោយរៀបរាប់អំពីព័ត៌មាន ឬឯកសារដែលត្រូវការបន្ថែម។

    b. *ពាក្យស្នើសុំពេញលេញ៖* ប្រសិនបើអ្នកជំងឺ និង/ឬសមាជិកគ្រួសាររបស់អ្នកជំងឺដាក់បញ្ជូនពាក្យស្នើសុំជំនួយហិរញ្ញវត្ថុពេញលេញ MHSHK នឹងផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរថា ឯកសារដែលត្រូវពឹងផ្អែកលើដើម្បីសម្រេចថាតើអ្នកជំងឺមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុដែរឬទេ ឱ្យបានទាន់ពេលវេលា និងជូនដំណឹងដល់អ្នកជំងឺជាលាយលក្ខណ៍អក្សរអំពីការសម្រេចនោះ (បើមាន រួមទាំងជំនួយដែលអ្នកជំងឺមានសិទ្ធិទទួលបាន)

និងមូលហេតុនៃការសម្រេចបែបនេះ។ ការជូនដំណឹងនេះក៏នឹងបញ្ចូលចំនួនភាគរយជំនួយហិរញ្ញវត្ថុ (សម្រាប់ពាក្យស្នើសុំដែលបានអនុម័ត) ឬហេតុផលនៃការបដិសេធ និងចំនួនបង់ប្រាក់ដែលបានរំពឹងទុកពីអ្នកជំងឺ និង/ឬគ្រួសារតាមជាក់ស្តែង។ អ្នកជំងឺ និង/ឬគ្រួសារនឹងបន្តទទួលបានសេចក្តីបញ្ជាក់ក្នុងអំឡុងពេលនៃការវាយតម្លៃពាក្យស្នើសុំពេញលេញ។

c. *សេចក្តីបញ្ជាក់របស់អ្នកជំងឺ៖* MHSHK នឹងផ្ញើកម្រងសេចក្តីបញ្ជាក់ដែលរៀបរាប់អំពីគណនីរបស់អ្នកជំងឺ និងចំនួនដែលជំពាក់។ សេចក្តីបញ្ជាក់របស់អ្នកជំងឺនឹងរួមបញ្ចូលការស្នើសុំឱ្យអ្នកជំងឺទទួលខុសត្រូវក្នុងការប្រាប់ MHSHK អំពីការធានារ៉ាប់រងសុខភាព សេចក្តីជូនដំណឹងអំពី MHSHK FAP លេខទូរស័ព្ទដើម្បីស្នើសុំជំនួយហិរញ្ញវត្ថុ និងអាសយដ្ឋានគេហទំព័រដែលឯកសារ FAP អាចទទួលបាន។

d. *គេហទំព័រ MHSHK៖* គេហទំព័រ MHSHK នឹងចុះផ្សាយសេចក្តីជូនដំណឹងនៅក្នុងកន្លែងដ៏លេចធ្លោដែលមានជំនួយហិរញ្ញវត្ថុជាមួយនឹងការពន្យល់អំពីដំណើរការដាក់ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុ។ MHSHK នឹងចុះផ្សាយ FAP នេះជាមួយនឹងបញ្ជីអ្នកផ្តល់សេវាដែលមានធានារ៉ាប់រង និងមិនមានធានារ៉ាប់រងក្រោម FAP សេចក្តីសង្ខេបជាភាសាសាមញ្ញ ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុ និងគោលនយោបាយបង់ប្រាក់និងប្រមូលប្រាក់នៅលើគេហទំព័រ MHSHK៖ http://www.memorialhermannkingwood.com/financial-assistance-program/. MHSHK នឹងមានច្បាប់ចម្លងឯកសារឥតគិតថ្លៃនៃឯកសារទាំងនេះតាមការស្នើសុំនៅផ្នែកសង្គ្រោះបន្ទាន់ និងតំបន់ចុះឈ្មោះ។

14. *អ្នកជំងឺមានធានារ៉ាប់រងមិនគ្រប់គ្រាន់៖* អ្នកជំងឺដែលមានធានារ៉ាប់រងទាំងមូល ឬដោយផ្នែកនៅក្រោមគោលនយោបាយធានារ៉ាប់រង ដែលដោយសារត្រូវទទួលបានការថែទាំបន្ទាន់ ឬព្យាបាលចាំបាច់ផ្នែកវេជ្ជសាស្ត្រ មានការចំណាយមិនបានសំណងមកវិញដែលហួសពីសមត្ថភាពរបស់ពួកគេក្នុងការទូទាត់សមតុល្យដែលនៅសល់សម្រាប់ការថែទាំដែលទទួលបាន។

15. *អ្នកជំងឺមិនមានធានារ៉ាប់រង៖* អ្នកជំងឺដែលមិនមានធានារ៉ាប់រងទាំងមូល ឬដោយផ្នែកក្រោមគោលនយោបាយធានារ៉ាប់រងសុខភាពនិងមិនមែនជាអ្នកទទួលផលប្រយោជន៍នៅក្រោមការធានារ៉ាប់រងសុខភាពសាធារណៈ ឬឯកជន ផលប្រយោជន៍សុខភាព ឬកម្មវិធីធានារ៉ាប់រងសុខភាពផ្សេងទៀត (រួមទាំងការធានារ៉ាប់រងឯកជន Medicare ឬ Medicaid ឬជំនួយជនរងគ្រោះដោយបទឧក្រិដ្ឋ) និងអ្នកដោយរងរបួសមិនអាចទទួលបានសំណងជំងឺចិត្តចំពោះគោលបំណងនៃសំណងការងារ ការធានារ៉ាប់រងរថយន្ត ឬការទទួលខុសត្រូវ ឬការធានារ៉ាប់រងភាគីទីបីផ្សេងទៀត ដូចដែលបានកំណត់ដោយ MHSHK ដោយផ្អែកលើឯកសារ និងព័ត៌មានដែលផ្តល់ដោយអ្នកជំងឺ ឬទទួលបានពីប្រភពផ្សេងៗទៀតសម្រាប់ការបង់ថ្លៃសេវាថែទាំសុខភាពដែលផ្តល់ដោយ MHSHK។

## **លក្ខណវិនិច្ឆ័យក្នុងការត្រួតពិនិត្យ៖**

1. ការទំនាក់ទំនង៖ ដើម្បីឱ្យអ្នកជំងឺ ក្រុមគ្រួសារ និងសហគមន៍របស់យើងកាន់តែយល់ដឹងពីលទ្ធភាពទទួលបានជំនួយហិរញ្ញវត្ថុ

MHSHK នឹងអនុវត្តជំហានមួយចំនួនដើម្បីជូនដំណឹងដល់អ្នកជំងឺ និងភ្ញៀវមន្ទីរពេទ្យរបស់ខ្លួនអំពីលទ្ធភាពទទួលបានជំនួយហិរញ្ញវត្ថុ និងផ្សព្វផ្សាយជាសាធារណៈអំពី FAP នេះ ដល់សមាជិកនៅក្នុងសហគមន៍ដែលបានបម្រើនៅមន្ទីរពេទ្យនីមួយៗឱ្យបានកាន់តែទូលំទូលាយ។ វិធានការទាំងនេះរួមមានៈ

a. *ការយល់ព្រមពីអ្នកជំងឺៈ* ការយល់ព្រមលើការថែទាំសុខភាពដែលត្រូវបានចុះហត្ថលេខានៅពេលចុះឈ្មោះសម្រាប់សេវាថែទាំសុខភាពរួមបញ្ចូលទាំងសេចក្តីបញ្ជាក់ថាបើសិនជាសេវាកម្មសប្បុរសធម៌ត្រូវបានទាមទារ ការស្នើសុំសិទ្ធិទទួលបានគួរតែត្រូវបានស្នើសុំនៅពេលចូលមន្ទីរពេទ្យ ឬនៅពេលទទួលបានវិក្កយបត្រ ឬរបាយការណ៍។

b. *ការប្រឹក្សាអំពីហិរញ្ញវត្ថុៈ* អ្នកជំងឺ MHSHK ត្រូវបានលើកទឹកចិត្តឱ្យស្វែងរកព័ត៌មានពីអ្នកផ្តល់ប្រឹក្សាផ្នែកហិរញ្ញវត្ថុរបស់មន្ទីរពេទ្យប្រសិនបើពួកគេគិតថានឹងមានការលំបាកក្នុងការចំណាយលើចំណែកថ្លៃមន្ទីរពេទ្យរបស់ពួកគេ។ អ្នកផ្តល់ប្រឹក្សាផ្នែកហិរញ្ញវត្ថុរបស់យើងនឹងខិតខំប្រឹងប្រែងដើម្បីជួយដល់អ្នកជំងឺដែលមិនមានការធានារ៉ាប់រង មានការធានារ៉ាប់រងមិនគ្រប់គ្រាន់ ឬប្រឈមនឹងបញ្ហាហិរញ្ញវត្ថុដទៃទៀតដែលទាក់ទងនឹងការបង់ថ្លៃសេវាថែទាំសុខភាពដែលយើងផ្តល់ជូន។ អ្នកផ្តល់យោបល់ផ្នែកហិរញ្ញវត្ថុអាចពិនិត្យមើលអ្នកជំងឺដែលអាចមានសិទ្ធិទទួលបានកម្មវិធីទទួលបានមូលនិធិពីរដ្ឋាភិបាលផ្សេងៗ ជួយឱ្យទទួលបានប្រាក់សំណងការងារ ឬទាមទារការទទួលខុសត្រូវ ជួយរៀបចំគម្រោងទូទាត់ប្រាក់រយៈពេលវែង ឬជួយអ្នកជំងឺដាក់ពាក្យសុំជំនួយហិរញ្ញវត្ថុ។

c. *សេចក្តីសង្ខេបជាភាសាសាមញ្ញងាយយល់ និងពាក្យស្នើសុំៈ* ច្បាប់ថតចម្លងនៃសេចក្តីសង្ខេបជាភាសាសាមញ្ញងាយយល់នៃ FAP របស់ MHSHK និងច្បាប់ថតចម្លងនៃពាក្យស្នើសុំជំនួយហិរញ្ញវត្ថុ នឹងដាក់ឱ្យអ្នកជំងឺទាំងអស់អាចរកបាននៅពេលមកទទួលសេវាផ្ទាល់ស្តែង។ MHSHK នឹងមានច្បាប់ចម្លងឯកសារឥតគិតថ្លៃនៃឯកសារទាំងនេះ តាមការស្នើសុំនៅផ្នែកសង្គ្រោះបន្ទាន់ និងតំបន់ចុះឈ្មោះ។ ច្បាប់ចម្លងដោយឥតគិតថ្លៃក៏អាចរកបានផងដែរតាមរយៈអ៊ីម៉ែល ឬហៅមកលេខ 281-312-4012 ឬ 281-312-4000 ជម្រើសទី 5 ។

d. *មានច្បាប់ចម្លងដែលបានបកប្រែៈ* MHSHK បកប្រែ FAP របស់ខ្លួន សេចក្តីសង្ខេបជាភាសាសាមញ្ញងាយយល់ ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុ និងគោលនយោបាយទូទាត់ប្រាក់ និងប្រមូលប្រាក់ សម្រាប់អ្នកចេះភាសាអង់គ្លេសតិចតួចតំណាងឱ្យតិចជាង 5 ភាគរយ (5%) ឬបុគ្គលចំនួន 1,000 នាក់នៅក្នុងសហគមន៍ដែលមន្ទីរពេទ្យរបស់ខ្លួនបានបម្រើ។ MHSHK នឹងចម្លងឯកសារទាំងនេះដោយឥតគិតថ្លៃដែលអាចរកបាននៅលើគេហទំព័រ MHSHK និងតាមការស្នើសុំនៅក្នុងមន្ទីរសង្គ្រោះបន្ទាន់ និងតំបន់ចុះឈ្មោះរបស់មន្ទីរពេទ្យ។ ច្បាប់ចម្លងដោយឥតគិតថ្លៃក៏អាចរកបានផងដែរតាមរយៈម៉េល ឬដោយការហៅមកលេខ 281-312-4012 ឬ 281-312-4000 ជម្រើសទី 5។

e. *សញ្ញា៖* រាល់ជំនួយផ្នែកហិរញ្ញវត្ថុទាំងអស់នឹងត្រូវបានចុះផ្សាយយ៉ាងច្បាស់ និងគួរឱ្យកត់សម្គាល់នៅក្នុងទីតាំងដែលសាធារណជនអាចមើលឃើញរួមទាំង ប៉ុន្តែមិនកំណត់ចំពោះផ្នែកសង្គ្រោះបន្ទាន់ និងកន្លែងចុះឈ្មោះអ្នកជំងឺ។ ផ្លាកសញ្ញានឹងបង្ហាញថាមានជំនួយហិរញ្ញវត្ថុ និងលេខទូរស័ព្ទទាក់ទងទីប្រឹក្សាហិរញ្ញវត្ថុសម្រាប់ព័ត៌មានបន្ថែម។

f. *គេហទំព័រ៖* គេហទំព័ររបស់ MHSHK នឹងបង្ហោះសេចក្តីជូនដំណឹងនៅកន្លែងដែលងាយមើលឃើញ ដោយប្រាប់ថា មានជំនួយហិរញ្ញវត្ថុ ដោយមានការពន្យល់អំពីដំណើរការនៃការស្នើសុំជំនួយហិរញ្ញវត្ថុ។ MHSHK នឹងបង្ហោះ FAP របស់ខ្លួនជាមួយបញ្ជីអ្នកផ្តល់សេវាដែលត្រូវបានរួមបញ្ចូល និងមិនរួមបញ្ចូលក្នុង FAP សេចក្តីសង្ខេបជាភាសាសាមញ្ញ ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុ និងគោលនយោបាយទូទាត់ប្រាក់ និងប្រមូលប្រាក់នៅលើគេហទំព័ររបស់ MHSHK៖ http://www.memorialhermannkingwood.com/financial-assistance-program/

g. *វិក្កយបត្រ និងសេចក្តីបញ្ជាក់របស់អ្នកជំងឺ៖* សេចក្តីបញ្ជាក់របស់អ្នកជំងឺនឹងរួមបញ្ចូលសំណើដែលអ្នកជំងឺត្រូវទទួលខុសត្រូវក្នុងការជូនដំណឹងដល់ MHSHK អំពីការធានារ៉ាប់រងសុខភាពដែលមាន ហើយនឹងរួមបញ្ចូលការជូនដំណឹងអំពី MHSHK FAP លេខទូរស័ព្ទដើម្បីស្នើសុំជំនួយហិរញ្ញវត្ថុ និងអាសយដ្ឋានគេហទំព័រដែលជាឯកសារអាចទទួលបាន។

h. សំបុត្រ ឬទូរសារ៖ អ្នកជំងឺអាចផ្ញើតាមប៉ុស្តិ៍ ឬបញ្ជូនទូរសារសំណើជាលាយលក្ខណ៍អក្សរសុំច្បាប់ចម្លងដោយឥតគិតថ្លៃទៅអាសយដ្ឋានខាងក្រោម ដោយបញ្ចូលទាំងឈ្មោះពេញរបស់បុគ្គល ហើយផ្តល់អាសយដ្ឋានផ្ញើរសំបុត្រដែលពួកគេចង់ឱ្យ MHSHK ផ្ញើច្បាប់ចម្លងមកឱ្យ។

Memorial Hermann Surgical Hospital Kingwood
Attn: Financial Assistance
300 Kingwood Medical Drive
Suite 100
Kingwood, Texas 77339
ទូរសារ: 281-358-2461

2. *ការកំណត់សិទ្ធិដែលអាចទទួលបាន៖* ជំនួយហិរញ្ញវត្ថុត្រូវបានកំណត់ដោយអនុលោមតាមនីតិវិធីដែលពាក់ព័ន្ធនឹងការវាយតម្លៃអំពីតម្រូវការហិរញ្ញវត្ថុរបស់បុគ្គល។ នីតិវិធីទាំងនោះត្រូវបានពិពណ៌នាដូចខាងក្រោម៖

a) ដំណើរការនៃការស្នើសុំជំនួយហិរញ្ញវត្ថុដែលអ្នកជំងឺ ឬអ្នកធានាត្រូវបានរំពឹងទុកថានឹងសហការ និងផ្តល់ព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានហិរញ្ញវត្ថុ និងឯកសារពាក់ព័ន្ធនឹងការកំណត់ពីតម្រូវការហិរញ្ញវត្ថុ។

b) MHSHK នឹងខិតខំប្រឹងប្រែងដោយសមហេតុផលដើម្បីកំណត់ថាតើបុគ្គលម្នាក់ៗគឺជា FAP ដែលមានសិទ្ធិ ដែរ ឬទេ ដើម្បីបញ្ចូលការជូនដំណឹងដល់អ្នកជំងឺអំពី FAP របស់ MHSHK នៅក្នុងសេចក្តីសង្ខេបជាភាសាសាមញ្ញងាយយល់មុនពេលចេញពីមន្ទីរពេទ្យ។ លើសពីនេះ MHSHK នឹងចាត់វិធានការដូចខាងក្រោម ដើម្បីជូនដំណឹងដល់អ្នកជំងឺអំពី FAP របស់ MHSHK៖

i) *ពាក្យស្នើសុំមិនពេញលេញ៖* ប្រសិនបើអ្នកជំងឺ និង/ឬក្រុមគ្រួសារដាក់ពាក្យស្នើសុំមិនពេញលេញ MHSHK នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរដែលពិពណ៌នាអំពីព័ត៌មាន ឬឯកសារបន្ថែមដែលត្រូវការក្នុងរយៈពេលសែសិបប្រាំ (45) ថ្ងៃ បន្ទាប់ពីទទួលបានការស្នើសុំដំបូង។

ii) *សេចក្តីបញ្ជាក់របស់អ្នកជំងឺ៖* សេចក្តីបញ្ជាក់របស់អ្នកជំងឺនឹងរួមបញ្ចូលសេចក្តីថ្លែងការណ៍ថា អ្នកជំងឺទទួលខុសត្រូវក្នុងការជូនដំណឹងដល់ MHSHK អំពីការធានារ៉ាប់រងសុខភាពដែលមានផ្តល់ជូនណាមួយ ហើយនឹងរួមបញ្ចូលសេចក្តីជូនដំណឹងអំពី FAP របស់ MHSHK លេខទូរស័ព្ទដើម្បីស្នើសុំជំនួយហិរញ្ញវត្ថុ និងអាសយដ្ឋានគេហទំព័រដែលអាចទទួលបានឯកសារ FAP។

iii) *គេហទំព័រ MHSHK៖* គេហទំព័ររបស់ MHSHK នឹងបង្ហោះសេចក្តីជូនដំណឹងនៅកន្លែងដែលងាយមើលឃើញ ដោយប្រាប់ថា មានជំនួយហិរញ្ញវត្ថុ ដោយមានការពន្យល់អំពីដំណើរការនៃការស្នើសុំជំនួយហិរញ្ញវត្ថុ។ នៅលើគេហទំព័រ MHSHK៖ http://www.memorialhermannkingwood.com/financial-assistance-program/ MHSHK នឹងចុះផ្សាយ FAP របស់ខ្លួនជាមួយនឹងបញ្ជីអ្នកផ្តល់សេវាដែលមានធានារ៉ាប់រង និងគ្មានធានារ៉ាប់រងក្រោម FAP សេចក្តីសង្ខេបជាភាសាសាមញ្ញងាយយល់ ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុ និងគោលនយោបាយទូទាត់ប្រាក់ និងប្រមូលប្រាក់របស់ខ្លួន។

iv) *ឯកសាររកបានតាមការស្នើសុំ* MHSHK នឹងមានច្បាប់ចម្លងដោយឥតគិតថ្លៃនៃ FAP របស់ខ្លួនជាមួយបញ្ជីអ្នកផ្តល់សេវាដែលត្រូវបានរួមបញ្ចូល និងមិនរួមបញ្ចូលនៅក្រោម FAP សេចក្តីសង្ខេបជាភាសាសាមញ្ញងាយយល់ ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុ និងគោលនយោបាយទូទាត់ប្រាក់ និងប្រមូលប្រាក់របស់ខ្លួនអាចផ្តល់ជូនបាននៅពេលស្នើសុំនៅផ្នែកសង្គ្រោះបន្ទាន់ និងកន្លែងចុះឈ្មោះ។

c) ការប្រើប្រាស់ប្រភពទិន្នន័យដែលអាចរកបានជាសាធារណៈនៅខាងក្រៅដែលផ្តល់ព័ត៌មានអំពីលទ្ធភាពបង់ប្រាក់របស់អ្នកជំងឺ ឬអ្នកធានារួមទាំងពិន្ទុឥណទានតាមរយៈ TransUnion ឬ Experian។

d) ការពិនិត្យឡើងវិញនូវគណនីទទួលមិនទាន់ទូទាត់រួចរបស់អ្នកជំងឺសម្រាប់សេវាកម្មមុនដែលប្រគល់ទៅអោយ MHSHK និងការទូទាត់ ឬប្រវត្តិជំពាក់មិនសងរបស់អ្នកជំងឺ។

e) កម្រិតនៃជំនួយហិរញ្ញប្បទានដែលផ្តល់ដោយ MHSHK គឺផ្អែកលើប្រាក់ចំណូល ទំហំគ្រួសារ និង FPL។ ទាំងអ្នកជំងឺដែលមានធានារ៉ាប់រង និងគ្មានធានារ៉ាប់រងអាចស្នើសុំជំនួយហិរញ្ញវត្ថុ និង

f) សិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុរបស់អ្នកជំងឺនឹងផ្អែកលើលក្ខណៈវិនិច្ឆ័យខាងក្រោម និងអាចប្រែប្រួលទៅតាមស្ថានភាពហិរញ្ញវត្ថុរបស់អ្នកជំងឺ ស្ថានភាពហិរញ្ញវត្ថុប្រសើរ និងលទ្ធភាពនៃការធានារ៉ាប់រងសុខភាពរបស់ភាគីទីបី។ គោលការណ៍ណែនាំសិទ្ធទទួលបាននឹងត្រូវត្រួតពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ បន្ទាប់ពីគោលការណ៍ណែនាំ FPL ត្រូវបានបោះពុម្ពផ្សាយដោយរដ្ឋាភិបាល។ គ្រួសារដែលមានប្រាក់ចំណូលលើសពីគោលការណ៍ណែនាំដែលបានចែងខាងលើអាចត្រូវបានត្រួតពិនិត្យសម្រាប់ការពិចារណាផែនការទូទាត់ប្រាក់។

3. *សិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុរបស់អ្នកជំងឺ៖* ផ្អែកលើ FPLs លក្ខណៈវិនិច្ឆ័យខាងក្រោមគួរត្រូវប្រើដើម្បីកំណត់ការបញ្ចុះតម្លៃដែលផ្តល់ជូនដល់អ្នកជំ

ជំងឺដែលមិនមានធានារ៉ាប់រង
និងមានធានារ៉ាប់រងមិនគ្រប់គ្រាន់ដែលមានសិទ្ធិទទួលជំនួយហិរញ្ញវត្ថុ។
អ្នកជំងឺមានធានារ៉ាប់រងមិនគ្រប់គ្រាន់ត្រូវតែមានវិក្កយបត្រធានារ៉ាប់រងរបស់ពួកគេមុនពេលមានសិទ្ធិទទួលសប្បុរសធម៌។
ការបញ្ចុះតម្លៃដែលផ្តល់ជូនអ្នកជំងឺដែលមានសិទ្ធិទទួលជំនួយហិរញ្ញវត្ថុនឹងត្រូវបានពិនិត្យឡើងវិញជាមួយនឹងការកម្រិតភាគរយ AGB
ដើម្បីធានាថាអ្នកជំងឺមិនត្រូវបានគេគិតប្រាក់លើសពី AGB ។

a. **ការថែទាំមិនគិតថ្លៃ៖**

i. ប្រសិនបើប្រាក់ចំណូលគ្រួសារប្រចាំឆ្នាំសរុបរបស់អ្នកជំងឺដែលមិនមានធានារ៉ាប់រងមានចំនួនស្មើ ឬតិចជាង ពីររយភាគរយ (200%) នៃគោលការណ៍ណែនាំស្តីពីភាពក្រីក្រសហព័ន្ធដែលមានចែងក្នុងតារាងសិទ្ធិទទួលជំនួយហិរញ្ញវត្ថុប្រាក់ចំណូលសរុប (សេចក្តីថ្លែង A - ការគណនានូវចំនួនដែលត្រូវបង់ជាទូទៅ ) អ្នកជំងឺ (ឬភាគីទទួលខុសត្រូវផ្សេងទៀត) នឹងទទួលបានការថែទាំដោយឥតគិតថ្លៃ (បញ្ចុះតម្លៃ 100%) ហើយនឹងមិនជំពាក់ចំណែកណាមួយនៃសមតុល្យគណនីឡើយ។

ii. អ្នកជំងឺដែលមានធានារ៉ាប់រងសុខភាពបឋមតាមរយៈ Medicare និងមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការធានារ៉ាប់រងបន្ទាប់បន្សំតាមរយៈ Medicaid នឹងទទួលបានការបញ្ចុះតម្លៃមួយរយភាគរយ (100%) នៅគ្រប់សមតុល្យដែលនៅសល់បន្ទាប់ពីការចេញវិក័យប័ត្រ Medicaid និងទទួលបានសំណងមកវិញតាមការសម្រេចពី THMP ឬអ្នកបង់ថ្លៃសេវាគ្រប់គ្រង Medicaid ។

b. **ការថែទាំដែលទទួលបានការបញ្ចុះតម្លៃ៖**

i. អ្នកជំងឺ/បុគ្គលដែលមានចំណូលគ្រួសារសរុបប្រចាំឆ្នាំលើសពីពីររយភាគរយ (200%) ប៉ុន្តែមិនលើសពីបួនរយភាគរយ (400%) នៃគោលការណ៍ណែនាំស្តីពីភាពក្រីក្រសហព័ន្ធបច្ចុប្បន្នអាចមានសិទ្ធិទទួលបានការបញ្ចុះតម្លៃនៃចំនួនដែលត្រូវបង់ជាទូទៅ (AGB) ចំពោះអ្នកជំងឺមានធានារ៉ាប់រង។

ii. អ្នកជម្ងឺដែលមានសមតុល្យគណនីនៅមិនទាន់សងដែលបានជំពាក់នៅលើវិក័យប័ត្រមន្ទីរពេទ្យអាចមានសិទ្ធិបញ្ចុះតំលៃប្រសិនបើមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖ 1) សមតុល្យលើសពីដប់ភាគរយ (10%) នៃប្រាក់ចំណូលគ្រួសារសរុបប្រចាំឆ្នាំរបស់បុគ្គលនោះ 2) ពួកគេមិនអាចបង់ប្រាក់ទាំងអស់ ឬមួយភាគនៃសមតុល្យវិក្កយបត្រដែលនៅសល់ និង 3) សមតុល្យវិក្កយបត្រគឺយ៉ាងហោចណាស់ $ 5,000 ។ នៅក្នុងកាលៈទេសៈទាំងនេះអ្នកជំងឺ ឬអ្នកធានាត្រូវបានរំពឹងថានឹងសហការជាមួយដំណើរការ FAP និងផ្តល់ព័ត៌មានផ្ទាល់ខ្លួន ឬព័ត៌មានហិរញ្ញវត្ថុ និងឯកសារពាក់ព័ន្ធនឹងការកំណត់ការទទួលបានសិទ្ធិ។ ប្រសិនបើត្រូវបានអនុម័ត អ្នកជំងឺនឹងទទួលខុសត្រូវក្នុងការបង់ប្រាក់មិនច្រើនជាង ដប់ភាគរយ (10%) នៃប្រាក់ចំណូលគ្រួសារសរុបប្រចាំឆ្នាំរបស់ពួកគេចំពោះសមតុល្យគណនី

នៅមិនទាន់សងដែលនៅសេសសល់ឬការបញ្ចុះតម្លៃ AGB នឹងត្រូវបានអនុវត្តដែលមិនសូវមានអត្ថប្រយោជន៍ច្រើនសម្រាប់ស្ថានភាពហិរញ្ញវត្ថុរបស់អ្នកជំងឺ។

4. បន្ទាត់ពេលវេលាសិទ្ធិទទួលបាន៖

   a. ចំពោះអ្នកជំងឺដែលគ្មានធានារ៉ាប់រង ការកំណត់ជំហិរញ្ញវត្ថុ និង សិទ្ធិទទួលបានដែលបានសន្មត់នឹងមានប្រសិទ្ធភាពជាមុនសម្រាប់សមតុល្យទូទាត់ដោយខ្លួនឯងដោយបើកចំហរទាំងអស់ និងការថែទាំបច្ចុប្បន្ន។ ការទទួលបានសិទ្ធិរបស់អ្នកជំងឺនឹងត្រូវបានកំណត់ដោយផ្អែកលើកត្តានានាដែលបានបញ្ជាក់នៅក្នុងនីតិវិធីក្នុងផ្នែកទី 3 ហើយនឹងមិនមានភាពលំបាកសម្រាប់ការបង់ប្រាក់ឱ្យបានរហ័ស ឬទាន់ពេលវេលា។ លើសពីនេះ ចំពោះអ្នកជំងឺដែលបំពេញពាក្យស្នើសុំជំនួយហិរញ្ញវត្ថុនឹងទទួលបានជំនួយហិរញ្ញវត្ថុបន្ថែមក្នុងរយៈពេលប្រាំមួយខែដោយមិនចាំបាច់មានសកម្មភាពបន្ថែមដែលត្រូវការពីអ្នកជំងឺ។ អ្នកជំងឺត្រូវទាក់ទងទៅកាន់ MHSHK ចំពោះបម្រែបម្រួលព័ត៌មានស្ថានភាពហិរញ្ញវត្ថុរបស់អ្នកជំងឺដែលបានកើតឡើងក្នុងកំឡុងពេលប្រាំមួយ (6) ខែ ដែលអាចប៉ះពាល់ដល់ការសម្រេចផ្តល់សិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុក្នុងរយៈពេលសាមសិប (30) ថ្ងៃ នៃបម្រែបម្រួលនេះ។ ការមិនបានលាតត្រដាងពីព័ត៌មាននៃភាពប្រសើរឡើងរបស់អ្នកជំងឺពាក់ព័ន្ធនឹងប្រាក់ចំណូលគ្រួសារអាចចាត់ទុកជាមោឃៈនូវការផ្តល់ជំនួយហិរញ្ញវត្ថុណាមួយដោយ MHSHK បន្ទាប់ពីមានការរីកចម្រើនស្ថានភាពទាំងនោះ។

5. *សេវាចាំបាច់ផ្នែកវេជ្ជសាស្ត្រ ឬបន្ទាន់៖* ជំនួយហិរញ្ញវត្ថុត្រូវបានកំណត់ចំពោះសេវាកម្មចាំបាច់ផ្នែកវេជ្ជសាស្ត្រ ឬបន្ទាន់ដែលត្រូវបានផ្តល់ជូននៅក្នុងមន្ទីរពេទ្យ។ គ្មានអ្វីនៅក្នុងផ្នែកនេះមានគោលបំណងដើម្បីផ្លាស់ប្តូរកាតព្វកិច្ច ឬការអនុវត្តរបស់ MHSHK ដោយអនុលោមតាមច្បាប់របស់សហព័ន្ធ ឬរដ្ឋទាក់ទងនឹងការព្យាបាលនៃលក្ខខណ្ឌសុខភាពបន្ទាន់ដោយមិនគិតពីលទ្ធភាពបង់ប្រាក់របស់អ្នកជំងឺឡើយ។

6. *ដំណើរការពាក្យស្នើសុំ*

   a. *វិធីដាក់ពាក្យស្នើសុំ៖* ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុគួរត្រូវបានបំពេញ និងបញ្ជូនដោយភ្ជាប់មកមួយឯកសារការគាំទ្រ។ ច្បាប់ចម្លងនៃពាក្យស្នើសុំនេះអាចទាញយកបាននៅលើគេហទំព័រ MHSHK នៅ៖ [http://www.memorialhermannkingwood.com/financial-assistance-program.](http://www.memorialhermannkingwood.com/financial-assistance-program) ច្បាប់ចម្លងឥតគិតថ្លៃក៏មាននៅក្នុងផ្នែកសង្គ្រោះបន្ទាន់ និងកន្លែងចុះឈ្មោះរបស់មន្ទីរពេទ្យផងដែរ។ ច្បាប់ចម្លងដោយឥតគិតថ្លៃក៏អាចរកបានផងដែរតាមរយៈអ៊ីម៉ែល ឬហៅមកលេខ 281-312-4012 ឬ 281-312-4000 ជម្រើសទី 5 ។

   b. អ្នកស្នើសុំអាចផ្ញើឯកសារដែលបានបំពេញ និងឯកសារយោងទៅឱ្យទីប្រឹក្សាហិរញ្ញវត្ថុរបស់មន្ទីរពេទ្យ ឬអ៊ីមែលទៅគេទៅកាន់អាសយដ្ឋានដែលបានរាយខាងក្រោម។ អ្នកជំងឺអាចស្វែងរកទីប្រឹក្សាផ្នែកវេជ្ជសាស្ត្ររបស់មន្ទីរពេទ្យដោយទៅកាន់តុផ្តល់ព័ត៌មាន និងស្នើសុំនិយាយជាមួយអ្នកផ្តល់ប្រឹក្សាផ្នែកហិរញ្ញវត្ថុ។

ចំពោះសំណួរអំពីដំណើរការដាក់ពាក្យស្នើសុំ ការបំពេញបែបបទស្នើសុំ ឬដើម្បីពិនិត្យមើលស្ថានភាពដាក់ពាក្យស្នើសុំដែលបានបញ្ជូន អ្នកផ្តល់ប្រឹក្សាហិរញ្ញវត្ថុរបស់មន្ទីរពេទ្យអាចជួយដោយផ្ទាល់នៅមន្ទីរពេទ្យ ឬអ្នកអាចហៅទូរស័ព្ទមកលេខ 281-312-4012 ឬ 281 -312-4000 ជម្រើសទី 5 ។

c. កន្លែងដែលត្រូវផ្ញើពាក្យដែលបានបំពេញរួចរាល់

Memorial Hermann Surgical Hospital Kingwood
Attn: Financial Assistance
300 Kingwood Medical Drive
Suite 100
Kingwood, Texas 77339

-ឬ-

ទូរសារ៖ 281-358-2461

d. សំណើសុំពិចារណាសម្រាប់ជំនួយហិរញ្ញវត្ថុ ឬសិទ្ធិទទួលបានដែលបានសន្មត់អាចត្រូវបានផ្តួចផ្តើមដោយបុគ្គលណាមួយដូចខាងក្រោមក្នុងកំឡុងពេលស្នើសុំ៖ (i) អ្នកជំងឺ ឬអ្នកធានា (ii) អ្នកតំណាងអ្នកជំងឺ ឬអ្នកធានា (iii) អ្នកតំណាង MHSHK ដែលតំណាងឱ្យអ្នកជំងឺ/ពាក្យស្នើសុំ ឬ (iv) ពេទ្យជួយអ្នកជំងឺ។

e. ដោយមិនគិតពីការពិចារណាដែលគួសបញ្ជាក់នៅកន្លែងផ្សេងក្នុង FAP នេះ វាជាការទទួលខុសត្រូវរបស់អ្នកជំងឺក្នុងការសហការជាមួយ និងចូលរួមយ៉ាងពេញលេញនៅក្នុងដំណើរការស្នើសុំជំនួយហិរញ្ញវត្ថុ។ នេះរួមបញ្ចូលការផ្តល់ព័ត៌មានអំពីការធានារ៉ាប់រងសុខភាពភាគីទីបីដែលមានការផ្តល់ជូននូវឯកសារ និងលិខិតបញ្ជាក់ដែលចាំបាច់ត្រឹមត្រូវ និងទាន់ពេលវេលាដើម្បីដាក់ពាក្យស្នើសុំថវិកាតាមរយៈរដ្ឋាភិបាល ឬកម្មវិធីផ្សេងទៀត (ឧ. Medicare, Medicaid, ការទទួលខុសត្រូវរបស់ភាគីទីបី, មូលនិធិជនរងគ្រោះដោយឧក្រិដ្ឋកម្ម។ ល។) ឬដើម្បីកំណត់សិទ្ធិទទួលបានរបស់អ្នកជំងឺចំពោះជំនួយហិរញ្ញវត្ថុផ្សេងទៀត។ ការខកខានមិនបានធ្វើដូច្នេះអាចជះឥទ្ធិពលអវិជ្ជមានទៅលើការពិចារណាលើពាក្យស្នើសុំជំនួយហិរញ្ញវត្ថុរបស់អ្នកជំងឺ។ អ្នកជំងឺត្រូវបានស្នើសុំឱ្យផ្តល់ព័ត៌មានលិខិតបញ្ជាក់ និងឯកសារក្នុងអំឡុងពេលសាមសិប (30) ថ្ងៃ នៃការស្នើសុំរបស់ MHSHK ប្រសិនបើពុំមានហេតុផលរឹងមាំត្រូវបានយកមកធ្វើឱ្យ MHSHK ចាប់អារម្មណ៍នោះទេ។ ពាក្យស្នើសុំជំនួយផ្នែកហិរញ្ញវត្ថុត្រូវតែបំពេញ និងចុះហត្ថលេខាដោយអ្នកជំងឺ (ឬអ្នកធានា / អ្នកតំណាង) ។

f. ទីប្រឹក្សាហិរញ្ញវត្ថុអាចជួយអ្នកដាក់ពាក្យសុំក្នុងដំណើរការស្នើសុំជំនួយហិរញ្ញវត្ថុ។ ប្រសិនបើអ្នកជំងឺបានស្លាប់ ហើយភាគីដែលទទួលខុសត្រូវមិនត្រូវបានកំណត់អត្តសញ្ញាណ អ្នកតំណាង MHSHK អាចធ្វើការស្នើសុំ និងបំពេញពាក្យសុំដោយប្រើប្រាស់ព័ត៌មាន និងឯកសារដែលមាន។

8. *ប្រាក់ចំណូលគ្រួសារ៖*

a. អ្នកជំងឺអាចផ្តល់ឯកសារមួយ ឬច្រើនដូចខាងក្រោម ដើម្បីរៀបចំចំណូលគ្រួសារ ប្រសិនបើមានឯកសារបែបនេះ។ ប្រសិនបើមានមនុស្សច្រើនដែលមានការងារធ្វើច្រើនជាងម្នាក់នៅក្នុងគ្រួសាររបស់អ្នកជំងឺ មនុស្សម្នាក់ៗត្រូវតែដាក់ឯកសារមួយ ឬច្រើនខាងក្រោម:

i. លិខិតប្រកាសពន្ធលើប្រាក់ចំណូលសហព័ន្ធដែលបានដាក់ថ្មីៗ
ii. បែបបទ W-2 និង 1099 ថ្មីបំផុត
iii. បង្កាន់ដៃបើកប្រាក់ឈ្នួលថ្មីបំផុត (ឬ បើអាច ថតចម្លងសេចក្តីបញ្ជាក់គ្មានការងារធ្វើ លិខិតសន្តិសុខសង្គម ជាដើម។ល។)
iv. សេចក្តីបញ្ជាក់របស់និយោជកប្រសិនបើកប្រាក់ជាសាច់ប្រាក់ ឬ
v. ការបញ្ជាក់ផ្សេងទៀតពីភាគីទីបីដែលទាក់ទងនឹងប្រាក់ចំណូលគ្រួសារ។

b. ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុនឹងមិនត្រូវបានចាត់ទុកថាមិនពេញលេញទេដោយផ្អែកលើការមិនផ្តល់ឯកសារប្រសិនបើអ្នកជំងឺបានផ្តល់ឯកសារយ៉ាងហោចណាស់មួយដែលឆ្លុះបញ្ចាំងពីចំណូលសម្រាប់សមាជិកគ្រួសារនីមួយៗ (រួមទាំងអ្នកជំងឺ) ដែលបានរាយខាងលើ និងមានលិខិតបញ្ជាក់ដែលមានចុះហត្ថលេខា ឬ ក្នុងករណីអ្នកជំងឺមិនអាចផ្តល់ឯកសារបែបនេះបាន ប៉ុន្តែបានចុះហត្ថលេខាលើលិខិតបញ្ជាក់។

c. អ្នកដាក់ពាក្យសុំត្រូវតែចុះហត្ថលេខាលើលិខិតបញ្ជាក់នៃពាក្យស្នើសុំ។ MHSHK អាចលុបចោល ឬកែប្រែការប្តេជ្ញាចិត្តប្រសិនបើមានភស្តុតាងក្រោយៗបង្ហាញថាអ្នកដាក់ពាក្យសុំបានផ្តល់ព័ត៌មានមិនពិត។

*ឯកសារបន្ថែម៖* FAP របស់ MHSHK មិនតម្រូវឱ្យមានឯកសារទ្រព្យសម្បត្តិ ឬការចំណាយទេ។ ប៉ុន្តែ អ្នកដាក់ពាក្យសុំអាចជ្រើសរើសផ្តល់ឯកសារបន្ថែមទាក់ទងនឹងទ្រព្យសម្បត្តិ ការចំណាយ ប្រាក់ចំណូល ប្រាក់កម្ចីមិនទាន់បានសង ឬស្ថានភាពផ្សេងទៀតដែលនឹងបង្ហាញពីបញ្ហាហិរញ្ញវត្ថុដើម្បីគាំទ្រដល់សំណើរសុំជំនួយហិរញ្ញវត្ថុដែលស្មើ ឬច្រើនជាងចំនួនដែលពួកគេមានសិទ្ធិទទួលបានអនុលោមតាម FAP នេះ។

9. *ព័ត៌មានមិនពិត ឬក្លែងបន្លំ៖*
ប្រសិនបើវាត្រូវបានកំណត់ថាអ្នកដាក់ពាក្យបានផ្តល់ព័ត៌មានមិនពិត ឬក្លែងបន្លំដោយចេតនាទាក់ទងនឹងលទ្ធភាពរបស់ពួកគេក្នុងការបង់ថ្លៃលើការចំណាយលើការព្យាបាលវេជ្ជសាស្ត្រ MHSHK អាចនឹងបដិសេធពាក្យស្នើសុំបច្ចុប្បន្ន ឬអនាគតរបស់អ្នកដាក់ពាក្យ។ ក្នុងករណីមានការផ្តល់ព័ត៌មានក្លែងបន្លំដោយភាពមិនស្មោះត្រង់នោះ MHSHK នឹងធ្វើការសម្រេចចិត្តរបស់ខ្លួនដោយផ្អែកលើព័ត៌មានដែលបានកែតម្រូវ។ ប្រសិនបើជំនួយហិរញ្ញវត្ថុត្រូវបានផ្តល់ជូនដោយផ្អែកលើការផ្តល់ព័ត៌មានមិនពិតដោយចេតនារបស់អ្នកជំងឺរួចហើយ MHSHK អាចចាត់ទុកជាមោឃៈនូវការផ្តល់ជំនួយហិរញ្ញវត្ថុពីមុន ដែលក្នុងករណីនេះ MHSHK រក្សាសិទ្ធិស្របច្បាប់ក្នុងការស្នើសុំការទូទាត់ពីអ្នកជំងឺនូវចំនួនទឹកប្រាក់ដែលអាចនឹងត្រូវ

សង។ ប្រសិនបើការផ្តល់ព័ត៌មានមិនពិតកើតឡើងដោយអចេតនានោះ MHSHK នឹងត្រួតពិនិត្យមើលការសម្រេចចិត្តឡើងវិញ ដោយផ្អែកលើព័ត៌មានដែលបានកែតម្រូវ។

**ឯកសារយោងបន្ថែម៖**

គោលនយោបាយស្តីពីការផ្ទេរអ្នកជំងឺ (EMTALA និងការអនុលោមតាមច្បាប់ស្តីពីការផ្ទេរនៅតិចសាស)
សេចក្តីសង្ខេបជាភាសាសាមញ្ញងាយយល់អំពីជំនួយហិរញ្ញវត្ថុ
ពាក្យស្នើសុំជំនួយហិរញ្ញវត្ថុ
គោលនយោបាយគិតប្រាក់ និងប្រមូលប្រាក់

**ការបង្ហាញ៖**

សេចក្តីថ្លែង A - ការគណនានូវចំនួនដែលត្រូវបង់ជាទូទៅ

សេចក្តីថ្លែង B - គោលការណ៍ណែនាំភាពក្រីក្ររបស់សហព័ន្ធ

*តទៅទំព័របន្ទាប់។*

## សេចក្តីថ្លែង A - ការគណនានូវចំនួនដែលត្រូវបង់ជាទូទៅ

ចំនួនដែលត្រូវបង់ជាទូទៅផ្អែកលើវិក្កយបត្រនិងដំណើរការការចុះលេខឬអក្សរសម្ងាត់ដែល MHSHK ប្រើសម្រាប់ថ្លៃសម្រាប់បង់សេវា Medicare សម្រាប់ការសង្គ្រោះបន្ទាន់ឬសេវាវេជ្ជសាស្ត្រចាំបាច់។ ទឹកប្រាក់សរុបដែលបានអនុញ្ញាតពី Medicare នឹងត្រូវបានបែងចែកដោយការគិតប្រាក់សរុបសម្រាប់ការទាមទារបែបនេះហើយលេខនោះនឹងត្រូវដកពី 1 ដើម្បីគណនាភាគរយ AGB ។

**AGB % សម្រាប់ IP (អ្នកជំងឺដែលសំរាកក្នុងមន្ទីពេទ្យ) = ការបង់ប្រាក់ដែលអនុញ្ញាតអោយរបស់ Medicare IP / ការគិតថ្លៃសរុបរបស់ Medicare IP**
**AGB % សម្រាប់ OP (អ្នកជំងឺដែលបានទៅព្យាបាលនៅមន្ទីរពេទ្យ) = ការបង់ប្រាក់ដែលអនុញ្ញាតអោយរបស់ប Medicare OP / ការគិតថ្លៃសរុបរបស់ Medicare OP**

| មន្ទីរពេទ្យ | អ្នកជំងឺដែលសំរាកក្នុងមន្ទីពេទ្យ | អ្នកជំងឺដែលបានទៅព្យាបាលនៅមន្ទីរពេទ្យ |
|---|---|---|
| Memorial Hermann Surgical Hospital - Kingwood | 30% | 14% |

ឆ្នាំសារពើពន្ធ 2019 (កក្កដា 2018 – មិថុនា 2019) ចំនួនទឹកប្រាក់ AGB មានដូចខាងក្រោម៖

**ចំនួនដែលត្រូវបង់ជាទូទៅ OP៖ 14%**
**ចំនួនដែលត្រូវបង់ជាទូទៅ IP៖ 30%**

*តទៅទំព័របន្ទាប់។*

## សេចក្តីថ្លែង B – គោលការណ៍ណែនាំភាពក្រីក្ររបស់សហព័ន្ធ

តារាងសិទ្ធិទទួលជំនួយហិរញ្ញវត្ថុប្រាក់ចំណូលប្រចាំខែសរុបត្រូវបានកែនៅពេលការផ្លាស់ប្តូរត្រូវបានធ្វើឡើងចំពោះគោលការណ៍ណែនាំភាពក្រីក្ររបស់សហព័ន្ធ។ តារាងត្រូវបានធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ។

តារាងសិទ្ធិទទួលជំនួយហិរញ្ញវត្ថុប្រាក់ចំណូលប្រចាំខែសរុបមានន័យថាតារាងប្រាក់ចំណូលបច្ចុប្បន្នដែល MHSHKប្រើប្រាស់ក្នុងការកំណត់សិទ្ធិទទួលជំនួយហិរញ្ញវត្ថុក្រោម FAP នេះ។

តារាងសិទ្ធិទទួលជំនួយហិរញ្ញវត្ថុប្រាក់ចំណូលក្នុងគ្រួសារប្រចាំខែសរុបគឺផ្អែកលើគោលការណ៍ណែនាំភាពក្រីក្ររបស់សហព័ន្ធ និងតារាងសិទ្ធិទទួលបានថ្នាក់ស្រុករបស់មន្ទីរពេទ្យ Harris ខោនធីដែលត្រូវបានកែតម្រូវយូរៗម្តងដោយភ្នាក់ងាររដ្ឋាភិបាលទាំងនោះហើយបាននិយាយថាតារាងអាចរកបានសម្រាប់ការពិនិត្យមើលឡើងវិញ។

សូមមើលតារាងខាងក្រោម៖

**Memorial Hermann Surgical Hospital Kingwood**
តារាងសិទ្ធិទទួលជំនួយហិរញ្ញវត្ថុប្រាក់ចំណូលសរុប

គោលការណ៍ណែនាំភាពក្រីក្ររបស់សហព័ន្ធឆ្នាំ 2019 (FPG)
ប្រាក់ចំណូលប្រចាំខែ
ឬប្រចាំឆ្នាំសរុបដើម្បីមានសិទ្ធិទទួលបានជំនួយហិរញ្ញវត្ថុដោយផ្អែកលើទំហំគ្រួសារ។

| | 100% នៃ FPG | | 200% នៃ FPG | | 400% FPG | |
|---|---|---|---|---|---|---|
| ទំហំ គ្រួសារ | ចំណូល ប្រចាំឆ្នាំ | ចំណូល ប្រចាំខែ | ចំណូល ប្រចាំឆ្នាំ | ចំណូល ប្រចាំខែ | ចំណូល ប្រចាំឆ្នាំ | ចំណូល ប្រចាំខែ |
| 1 | $12,490 | $1,041 | $24,980 | $2,082 | $49,960 | $4,163 |
| 2 | $16,910 | $1,409 | $33,820 | $2,818 | $67,640 | $5,637 |
| 3 | $21,330 | $1,778 | $42,660 | $3,555 | $85,320 | $7,110 |
| 4 | $25,750 | $2,146 | $51,500 | $4,292 | $103,000 | $8,583 |
| 5 | $30,170 | $2,514 | $60,340 | $5,028 | $120,680 | $10,057 |
| 6 | $34,590 | $2,883 | $69,180 | $5,765 | $138,360 | $11,530 |
| 7 | $39,010 | $3,251 | $78,020 | $6,502 | $156,040 | $13,003 |
| 8 | $43,430 | $3,619 | $86,860 | $7,238 | $173,720 | $14,477 |

*សម្រាប់សមាជិកលើសពី 8 នាក់, បន្ថែម $4,420 សម្រាប់មនុស្សបន្ថែមម្នាក់ៗដើម្បីកំណត់គោលការណ៍ណែនាំភាពក្រីក្ររបស់សហព័ន្ធ។*